អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១២

# សេចក្តីប្រកាសព័ត៌មាន

## អង្គជំនុំជម្រះសាលាដំបូងផ្អាកសវនាការលើសំណុំរឿង ០០២

បន្ទាប់ពីបញ្ចប់សវនាការសាធារណៈនៅរសៀលថ្ងៃនេះ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានផ្អាកសវនាការលើសំណុំរឿង ០០២ និងលើកទៅបន្តធ្វើនៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១២។ សវនាការនឹងបន្តធ្វើនៅម៉ោង ៩ព្រឹក ថ្ងៃច័ន្ទ ទី១៦ ខែកក្កដា ដោយស្តាប់សក្ខីកម្មរបស់លោកបណ្ឌិត ដេវីដ ឆេនដល័រ។

ចាប់តាំងពីការអានសេចក្តីសន្និដ្ឋានលើបទចោទប្រកាន់ក្នុងសំណុំរឿង ០០២ កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានដំណើរការសវនាការរយៈពេលសរុបចំនួន ៧៨ថ្ងៃ។ គិតត្រឹមថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានស្តាប់សក្ខីកម្មរបស់សាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ចំនួន ១៨រូប។ សាធារណជនចំនួន ៤៣ ៦២៦ នាក់ បានចូលរួមតាមដានសវនាការលើសំណុំរឿង ០០២ ដោយផ្ទាល់នៅ អ.វ.ត.ក។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោក ឡាស អូលសិន**
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
ទូរស័ព្ទដៃ: +៨៥៥ (0)១២ ៤៨៨ ០២៣
សារអេឡិកត្រូនិក: olsenl@un.org

**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យ អ.វ.ត.ក
ទូរស័ព្ទដៃ: +៨៥៥ (0)១២ ៤៨៨ ១៥៦
សារអេឡិចត្រូនិក: neth.pheaktra@eccc.gov.kh